


ព័ត៌មានកម្មវិធី SPCR

# ការប្រែប្រួលអាកាសធាតុ

ADB

អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព
កម្មវិធីយុទ្ធសាស្ត្រសម្រាប់ភាពធន់នឹងអាកាសធាតុ (SPCR)

នាយកដ្ឋានប្រែប្រួលអាកាសធាតុ
ខែកញ្ញា ឆ្នាំ២០១៦ លេខ ៦

## ការចងក្រងការអនុវត្តការបន្ស៊ាំនឹងការប្រែប្រួលអាកាសធាតុនៅសហគមន៍ និង ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយនៅកម្ពុជា

ដោយមើលឃើញពីតម្រូវការដើម្បីបង្កើន និងផ្សព្វផ្សាយចំណេះដឹងស្តីពីវិធីសាស្ត្របន្ស៊ាំនឹងការប្រែប្រួលអាកាសធាតុដែលសមស្របសម្រាប់បរិបទប្រទេសកម្ពុជា នាយកដ្ឋានប្រែប្រួលអាកាសធាតុនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព កំពុងប្រកាសស្វែងរកការចូលរួមផ្សព្វផ្សាយជាករណីសិក្សាដែលមានចំនួនប្រហែល២ទំព័រស្តីពីការអនុវត្តការបន្ស៊ាំនឹងការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយក្រោមប្រធានបទ៖

១. **ការអនុវត្តជាលក្ខណៈប្រពៃណី/ជនជាតិដើមភាគតិចដើម្បីបន្ស៊ាំនឹងការប្រែប្រួលអាកាសធាតុ និងកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ៖** ករណីសិក្សាអាចជារចនាសម្ព័ន្ធ បច្ចេកទេស ឬការអនុវត្តរបស់ប្រជាជនក្នុងសហគមន៍ដើម្បីរៀបចំឬគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធ ធនធានធម្មជាតិ ជីវភាពរស់នៅឬការពារគ្រោះមហន្តរាយធំៗ (ទឹកជំនន់ គ្រោះរាំងស្ងួត ខ្យល់ព្យុះ)។ អាចជាវិធានការដែលប្រជាជនក្នុងសហគមន៍បានចាប់ផ្តើមបង្កើតដោយខ្លួនឯងដើម្បីឆ្លើយតបការកើនឡើងកម្តៅ ឬការប្រែប្រួលរបបទឹកភ្លៀង។

២. **ការអនុវត្តដែលផ្សព្វផ្សាយពីភាពធន់នឹងអាកាសធាតុ និងលើកកម្ពស់ស្ត្រី កុមារ និងយុវវ័យ៖** ករណីសិក្សាការអនុវត្តការបន្ស៊ាំនឹងការប្រែប្រួលអាកាសធាតុក្នុងសហគមន៍ដែលជាពិសេសជួយបង្កើនជីវភាពរស់នៅរបស់ស្ត្រី កុមារ យុវជន ឬកាត់បន្ថយភាពងាយរងគ្រោះនឹងការប្រែប្រួលអាកាសធាតុ។ គួរតែជាឧទាហរណ៍ដែលត្រូវបានអនុវត្ត ឬបង្កើតឡើងបន្ថែមទៀតដើម្បីបង្កើនភាពធន់នឹងអាកាសធាតុ និងកាត់បន្ថយហានិភ័យគ្រោះមហន្តរាយដល់ស្ត្រី កុមារ និងយុវវ័យ។

សេចក្តីប្រកាសស្វែងរកការចូលរួមផ្សព្វផ្សាយនេះ គឺបើកចំហដល់ក្រសួង-ស្ថាប័នរាជរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល អង្គការសង្គមស៊ីវិល អ្នកសិក្សាស្រាវជ្រាវនៅសាកលវិទ្យាល័យ សិស្ស-និស្សិត សហគមន៍ និងវិស័យឯកជននានានៅកម្ពុជា។ គណៈកម្មការនឹងពិនិត្យមើលករណីសិក្សាដែលបានផ្ញើមកដោយមន្ត្រីមកពីនាយកដ្ឋានប្រែប្រួលអាកាសធាតុ ក្រុមការងារបច្ចេកទេសនៃកម្មវិធីយុទ្ធសាស្ត្រសម្រាប់ភាពធន់នឹងអាកាសធាតុ កម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា និងអង្គការផ្លែន អន្តរជាតិ។ ករណីសិក្សាដែលបានចងក្រងល្អៗប្រហែលចំនួន១៥ នឹងត្រូវយកទៅផ្សព្វផ្សាយនៅក្នុង "សន្និសីទជាតិស្តីពីការអនុវត្តការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា" ដែលនឹងប្រព្រឹត្តទៅនៅខែវិច្ឆិកា ឆ្នាំ២០១៦ ខាងមុខនេះ។ ករណីសិក្សាទាំងនេះនឹងត្រូវបានចងក្រងបោះពុម្ពជាឯកសារដើម្បីផ្សព្វផ្សាយនៅថ្នាក់ជាតិ-ក្រោមជាតិ និងសហគមន៍ ព្រមទាំងនៅថ្នាក់អន្តរជាតិផងដែរ។

ទម្រង់សម្រាប់សរសេរអាចទាញយកពីគេហទំព័រ www.spcrcambodia.org/kh/ ឬ www.camclimate.org.kh

- សូមផ្ញើករណីសិក្សាជាភាសាខ្មែរ ឬអង់គ្លេសឱ្យបានមុនម៉ោង៥៖០០ល្ងាចនៅថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៦។
- សូមផ្ញើមកអាសយដ្ឋានអ៊ីម៉ែល adaptation_call@camclimate.org.kh ដោយសរសេរចំណងជើងអ៊ីម៉ែល "ការអនុវត្តការបន្សាំ"
- សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងតាមរយៈទូរស័ព្ទ 012 617 092 និង 077 535 392 ឬ អ៊ីម៉ែល adbspcrta8179@gmail.com ។

## នាយកដ្ឋានប្រែប្រួលអាកាសធាតុ បណ្តុះបណ្តាលក្រុមការងារការបន្សាំនឹងការប្រែប្រួលអាកាសធាតុ លើការវាយតម្លៃភាពងាយរងគ្រោះ និងការធ្វើផែនការបន្សាំ




មន្ត្រីចំនួនប្រមាណ៨០នាក់ ដែលអញ្ជើញមកពីបណ្តាក្រសួងស្ថាប័នពាក់ព័ន្ធ បានចូលរួមវគ្គបណ្តុះបណ្តាលចំនួន២លើកស្តីពីការវាយតម្លៃភាពងាយរងគ្រោះ និងការធ្វើផែនការបន្សាំនឹងការប្រែប្រួលអាកាសធាតុ សម្រាប់ការសិក្សាលម្អិតពីលទ្ធភាពក្នុងវិស័យកសិកម្ម ធនធានទឹក និងហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនទីក្រុង និងជនបទ កាលពីនៅថ្ងៃទី១៦ដល់ទី១៨ ខែសីហា នៅខេត្តព្រៃវែង និងថ្ងៃទី២៦ដល់ទី២៨ ខែកញ្ញា នៅខេត្តកំពង់ឆ្នាំង។

វគ្គបណ្តុះបណ្តាលនេះ ដឹកនាំដោយឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត សាបូ អូហ្សាណូ រដ្ឋលេខាធិការក្រសួងបរិស្ថាន និងជាប្រធានសម្របសម្រួលក្រុមការងារកម្មវិធីយុទ្ធសាស្ត្រសម្រាប់ភាពធន់នឹងអាកាសធាតុ (SPCR) និងឯកឧត្តម ប៉ុន សារឿន អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន និងជាអនុប្រធានសម្របសម្រួលក្រុមការងារកម្មវិធី SPCR។ វគ្គបណ្តុះបណ្តាលនេះ ត្រូវបានរៀបចំដោយនាយកដ្ឋានប្រែប្រួលអាកាសធាតុក្រោមគម្រោងការបញ្ជ្រាបភាពធន់នឹងអាកាសធាតុទៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍នៃកម្មវិធី SPCR ដោយមានកិច្ចសហការគាំទ្រពីឯកឧត្តម ម៉ុក ធារី អភិបាលរងនៃគណៈអភិបាលខេត្តព្រៃវែង និងលោកជំទាវ ប៉ាល់ យឿន អភិបាលរងនៃគណៈអភិបាលខេត្តកំពង់ឆ្នាំង ព្រមទាំងក្រសួងស្ថាប័នពាក់ព័ន្ធមួយចំនួនទៀតនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដែលអញ្ជើញមកពីខេត្តពោធិ៍សាត់ បាត់ដំបង ត្បូងឃ្មុំ ព្រៃវែង កំពង់ធំ និងកំពង់ឆ្នាំង។



សមាជិកក្រុមការងារ ការបន្សាំនឹងការប្រែប្រួលអាកាសធាតុដែលជាជនបង្គោលមកពីក្រសួងបរិស្ថាន ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងធនធានទឹក និងឧតុនិយម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងកិច្ចការនារី ក្រសួងផែនការ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ គណៈកម្មាធិការជាតិ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិនិងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាបានចូលរួមវគ្គបណ្តុះបណ្តាលទាំងពីរខាងលើនេះ។

អ្នកចូលរួមវគ្គបណ្តុះបណ្តាលបានចុះប្រមូលទិន្នន័យនៅបីឃុំ (កន្សោមអក ពោងជំរី និងបាប៉ោង) ក្នុងខេត្តព្រៃវែង និងបីឃុំទៀត (ដារ ច្រណូក និងកំពង់ហៅ) ក្នុងខេត្តកំពង់ឆ្នាំងដើម្បីស្វែងយល់ និងដកស្រង់ព័ត៌មានពាក់ព័ន្ធនឹងទឹកជំនន់ គ្រោះរាំងស្ងួត ខ្យល់ព្យុះ និងសីតុណ្ហភាព ដែលជាលំហាត់សាកល្បងវាយតម្លៃភាពងាយរងគ្រោះនឹងការប្រែប្រួលអាកាសធាតុ។ ទិន្នន័យដែលប្រមូលបាននឹងប្រើប្រាស់ជាព័ត៌មានដើមគ្រា សម្រាប់ការសិក្សាលម្អិតពីលទ្ធភាពក្នុងវិស័យកសិកម្ម ធនធានទឹក និងហេដ្ឋារចនាសម្ព័ន្ធដើម្បីសរសេរសំណើគម្រោងបន្សាំក្នុងការស្វែងរកមូលនិធិពីសហគមន៍អន្តរជាតិ។

គួរបញ្ជាក់ផងដែរថា នេះជាវគ្គបណ្តុះបណ្តាលលើកទី២ និងទី៣ ដែលមានកម្រិតស៊ីជម្រៅជាងការបណ្តុះបណ្តាលលើកទី១ ដែលបានរៀបចំឡើងនៅខេត្តបាត់ដំបងកាលពីចុងឆ្នាំ២០១៥។

បន្ថែមពីលើនេះ នៅក្នុងវេទិកាស្ដីពី “ការការពារ និងអភិរក្សធនធានធម្មជាតិ” នៅថ្ងៃទី២២ ខែសីហាឆ្នាំ២០១៦ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានប្រគល់ជូនក្រសួងចំនួន៦រួមមានក្រសួងបរិស្ថាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងរ៉ែ និងថាមពល ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្រសួងធនធានទឹក និងឧតុនិយម ដើម្បីធ្វើការឱ្យជិតស្និទ្ធជាមួយអង្គការសង្គមស៊ីវិលលើការការពារបរិស្ថាន និងថែទាំធនធានធម្មជាតិ និងបានកំណត់ឱ្យមានវេទិកាពិភាក្សារៀងរាល់៣ខែម្ដង។ **សម្ដេចតេជោ ហ៊ុនសែន** បានមានប្រសាសន៍បន្ថែមទៀតថា យន្តការនេះក៏អាចអនុវត្តនៅថ្នាក់ខេត្តផងដែរ។ ដើម្បីចូលរួមចំណែកដល់ការអនុវត្តសកម្មភាពនេះជាផ្នែកមួយក្រោមកម្មវិធី SPCR នៅកម្ពុជា គម្រោងអភិវឌ្ឍន៍សេដ្ឋកិច្ចក្រុងរបៀងនៅមហាអនុតំបន់ទន្លេមេគង្គ កំពុងអនុវត្តដោយក្រសួងបរិស្ថាន និងរដ្ឋបាលព្រៃឈើនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីគ្រប់គ្រងរបៀងជីវៈចម្រុះប្រកបដោយចីរភាពក្នុងខេត្តកោះកុង និងមណ្ឌលគិរី។

ចាប់តាំងពីចុងឆ្នាំ២០១៥ **សម្ដេចតេជោ ហ៊ុនសែន** បានប្រកាសឱ្យធ្វើអន្តរាគមន៍ខ្លាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិជួយដល់កសិករដែលរងគ្រោះធ្ងន់ធ្ងរដោយគ្រោះរាំងស្ងួតទូទាំងប្រទេស ដើម្បីចែកចាយទឹកដល់សហគមន៍ដែលរងគ្រោះជាពិសេសស្ត្រី ចាស់ជរា និងកុមារ។ ទន្ទឹមនេះដែរ ដើម្បីគាំទ្រដល់សកម្មភាពនេះ ក្រសួងបរិស្ថានបានធ្វើប្រតិភូកម្មមុខងារ “ការបញ្ជ្រាបភាពធន់នឹងអាកាសធាតុ” ជូនរដ្ឋបាលនៅថ្នាក់ក្រោមជាតិ។

ករណីសិក្សាខាងក្រោមបង្ហាញពីភាពប្រឈម និងដំណោះស្រាយនានាដែលបានស្នើឡើងពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុដែលសហគមន៍និងអាជ្ញាធរមូលដ្ឋានបានឱ្យដឹងកំឡុងពេលចុះប្រមូលព័ត៌មាន។

**កសិករកំណត់វិធានការដើម្បីបន្សាំនឹងគ្រោះរាំងស្ងួតក្នុងខេត្តព្រៃវែង៖** ជាទូទៅសហគមន៍ដែលសិក្ខាកាមបានចុះទៅជួប គឺប្រើប្រាស់ទឹកយកពីអណ្ដូងស្នប់ ស្រះដែលបានជីក ទន្លេ បឹង និងអាងស្តុកទឹកជាដើម។ ប្រធានឃុំបានមានប្រសាសន៍ថា “ឥឡូវនេះយើងមានទឹកសម្រាប់សហគមន៍ប្រើប្រាស់ ប៉ុន្តែបើសិនយើងមិនចាត់វិធានការពីឥឡូវទេ យើងនឹងជួបបញ្ហានៅរដូវវស្សា”។ សហគមន៍បានឱ្យដឹងពីសកម្មភាពមួយចំនួនដែលពួកគេបានដោះស្រាយនៅក្នុងសហគមន៍មានដូចជា៖

**បង្កើតក្រុមប្រើប្រាស់ទឹក៖** កសិករក្នុងសហគមន៍មើលឃើញភូមិផ្សេងៗមានការគ្រប់គ្រងទឹកបានល្អសម្រាប់ការប្រើប្រាស់លក្ខណៈជាក្រុម។ ពួកគាត់ចង់ទទួលបានការបណ្ដុះបណ្ដាលខ្លះៗពីការចងក្រងបង្កើតក្រុមកសិករប្រើប្រាស់ទឹក និងវិធីសាស្ត្រក្នុងការគ្រប់គ្រងទឹកឱ្យមាននិរន្តរភាពសម្រាប់ផលិតកម្មកសិកម្ម។

**អភិរក្សទឹក៖** សមាជិកសហគមន៍បានបង្ហាញពីតម្រូវការក្នុងការចូលរួមទាំងអស់គ្នា ដើម្បីប្រើប្រាស់ទឹកដោយសន្សំសំចៃ។ សហគមន៍ខ្លះបានសាងសង់ទំនប់តូចៗដើម្បីរក្សាទឹកទុក។ សកម្មភាពបែបនេះត្រូវការរៀបចំលក្ខណៈជាក្រុម ដូច្នេះទឹកនឹងត្រូវបានអភិរក្ស និងចែកចាយដោយមានប្រសិទ្ធភាពនៅក្នុងសហគមន៍របស់ពួកគាត់។

**ផ្លាស់ប្ដូរពូជដំណាំ៖** នៅប៉ុន្មានឆ្នាំថ្មីៗនេះ កសិករកាន់តែពឹងផ្អែកខ្លាំងលើអាងស្តុកទឹកសម្រាប់ការស្រោចស្រពដំណាំ ដែលធ្វើឱ្យពួកគាត់កាន់តែងាយរងគ្រោះ។ កសិករនៅតំបន់ងាយរងគ្រោះបានពន្យារពេលនៃការដាំដុះដំណាំព្រោះពួកគាត់យល់ថាអាចនឹងខាតបង់ដើមទុនប្រសិនបីចំណាយលើការដាំដុះដំណាំដោយសារអាកាសធាតុប្រែប្រួល។ កសិករបានផ្លាស់ប្ដូរទំលាប់របស់ពួកគាត់ពីការធ្វើស្រូវធ្ងន់មកស្រូវស្រាលវិញដោយសារចំណាយពេលខ្លី និងត្រូវការប្រើទឹកតិច ហើយអាចប្រមូលផលក្នុងរយៈពេល៣ខែប៉ុណ្ណោះ។

**ការប្រមូលទឹកភ្លៀងទុក៖** ស្ត្រីនៅក្នុងសហគមន៍ត្រូវទៅដឹកជញ្ជូនទឹក២ធុង(២៥លីត្រ/ធុង)ពីស្រះទឹកក្នុងវត្តដែលមានចម្ងាយប្រហែល២គីឡូម៉ែត្រពីផ្ទះរបស់ពួកគាត់ដោយត្រូវដឹកជញ្ជូនច្រើនដងក្នុងមួយថ្ងៃៗ។ គ្រួសារនីមួយៗត្រូវការបង្កើនចំនួនពាងទឹក និងជីកស្រះបន្ថែមដើម្បីរក្សាទឹកភ្លៀងទុកសម្រាប់ប្រើប្រាស់។

ខណៈដែលសហគមន៍អាចអនុវត្តសកម្មភាពបន្សាំមួយចំនួនដោយខ្លួនឯង ពួកគេត្រូវការការគាំទ្រពីអាជ្ញាធរមូលដ្ឋាន ដើម្បីចាប់ផ្ដើមការអនុវត្តថ្មីៗនេះ។ ឧទាហរណ៍ កសិករដឹងថាការប្រើប្រាស់ប្រព័ន្ធស្រោចស្រពដោយដំណក់ទឹកអាចជួយសន្សំទឹកបានច្រើន និងចំណេញពេលវេលា។ ប៉ុន្តែបច្ចេកវិទ្យានេះគឺត្រូវចំណាយថវិកាច្រើនសម្រាប់ពួកគាត់ ហើយអាចប្រើប្រាស់បានសម្រាប់ប្រភេទដំណាំដែលកសិករមិនសូវនិយមដាំ។ កសិករត្រូវការវគ្គបណ្ដុះបណ្ដាល និងជួយផ្ដល់បច្ចេកទេសទាំងនេះមុនពួកគាត់អាចផ្លាស់ប្ដូរទំលាប់នៃការដាំដុះទាំងនេះ។

សកម្មភាពបន្ទាន់ត្រូវការចាំបាច់ ដើម្បីស្ដារឡើងវិញ និងសាងសង់ប្រឡាយមេ និងប្រឡាយរង ឬអាងស្តុកទឹកសម្រាប់ផលិតកម្មកសិកម្ម និងការប្រើប្រាស់ប្រចាំថ្ងៃ។ ខណៈដែលកសិករអាចបូមទឹកសង្គ្រោះដំណាំ ប៉ុន្តែប្រសិនបើគ្មានប្រភពទឹកទេ កសិករមិនអាចធ្វើអ្វីបានឡើយ។ សហគមន៍ចង់ស្ដារឡើងវិញទំនប់ បឹង អាងស្តុកទឹក និងប្រឡាយដើម្បីឱ្យមានទឹកដែលអាចប្រើប្រាស់បានពេញមួយឆ្នាំ។

## ដំណោះស្រាយបញ្ហាផ្សារលិចទឹកក្នុងខេត្តកំពង់ឆ្នាំង ៖



ឃុំកំពង់ហៅស្ថិតក្នុងស្រុកកំពង់លែង ដែលអាចធ្វើដំណើរពីទីរួមខេត្តកំពង់ឆ្នាំង ប្រហែល៣០នាទីតាមសាឡាងចម្លង និងតាមផ្លូវគោកក្នុងរដូវប្រាំង ឬតាមសាឡាងចម្លងក្នុងរដូវវស្សា។ ប្រជាជនច្រើនជាង៩០% រស់នៅក្នុង ឃុំកំពង់ហៅជាកសិករ ហើយអ្នកខ្លះជាអ្នកលក់ដូរនៅផ្សារកំពង់ហៅ។ ផ្សារនេះលិចទឹកជារៀងរាល់ឆ្នាំរហូតដល់កម្ពស់២,៥ម៉ែត្រ ពីខែកក្កដារហូតដល់ខែធ្នូ ដោយសារការកើនឡើងកម្ពស់ទឹកនៃបឹងទន្លេសាប និងជំនន់មកពីភ្នំទូកមាស។ មានស្តង់លក់ដូរប្រហែលចំនួន១២០ទៅ១៣០ប៉ុណ្ណោះ សម្រាប់បម្រើដល់ប្រជាជនរស់នៅក្នុងឃុំចំនួនទាំង៩នៃស្រុកកំពង់លែងនេះ។ ហេដ្ឋារចនាសម្ព័ន្ធផ្សារត្រូវការឱ្យមានប្រព័ន្ធលូបង្ហូរ ការគ្រប់គ្រងកាកសំណល់ និងចំណតយានយន្តដើម្បីឱ្យមានបរិស្ថានល្អក្នុងរដូវវស្សា។

## អ្នកភូមិបានអនុវត្តវិធានការមួយចំនួន ដើម្បីការពារខ្យល់ព្យុះក្នុងខេត្តព្រៃវែង ៖



ឃុំកន្សោមអក ក្នុងស្រុកកំពង់ត្របែកនៅខេត្តព្រៃវែង សហគមន៍បានជួបប្រទះខ្យល់ព្យុះធ្ងន់ធ្ងរ និងសីតុណ្ហភាពឡើងក្តៅខ្លាំងហើយបានប៉ះពាល់ដល់ដំណាំរបស់ពួកគាត់។ ដោយសារបទពិសោធន៍បែបនេះ ពួកគាត់បានដាំដើមឈើ និងដើមឫស្សីព័ទ្ធជុំវិញផ្ទះ ហើយមានករណីខ្លះ កសិករបានប្រើប្រាស់ថ្នាំគីមីបាញ់លើដំណាំស្រូវកុំឱ្យលូតខ្ពស់ និងឱ្យដើមរឹងមាំដើម្បីធន់នឹងខ្យល់បក់ខ្លាំង។ នៅក្នុងតំបន់នេះ ការលើកទឹកចិត្តឱ្យដាំដើមឈើ និងដាំបន្លែដើម្បីទប់ទល់នឹងខ្យល់ព្យុះអាចជួយកាត់បន្ថយការប្រើប្រាស់ថ្នាំគីមី និងសន្សំថវិកានិងធ្វើឱ្យប្រសើរឡើងលក្ខខណ្ឌបរិស្ថាន ហើយកសិករខ្លះក៏បានសង់ទីទួលសុវត្ថិភាពផងដែរ ទោះបីយ៉ាងណា ការអនុវត្តទាំងនេះ វាត្រូវបានផ្តួចផ្តើមឡើងតាមផ្ទះនីមួយៗប៉ុណ្ណោះ។ ពួកគេមានលទ្ធភាពសង់ទីកន្លែងសុវត្ថិភាពដែលមានទំហំតូច និងមិនអាចអនុញ្ញាតឱ្យសមាជិកក្នុងគ្រួសារទាំងអស់ចូលជ្រកបានឡើយ។ អ្នកភូមិត្រូវការការគាំទ្រដើម្បីរៀបចំតំបន់សុវត្ថិភាពសម្រាប់ការជន្លៀសខ្លួនពេលមានខ្យល់ព្យុះ។

# សហគមន៍ព្រៃឈើក្រាំងសេរី ឃុំគិរីវន្ត ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ

កាលពីខែមិថុនា ឆ្នាំ២០១៦ កម្មវិធីសាកល្បងភាពធន់នឹងអាកាសធាតុបានគាំទ្រគម្រោងការបញ្ជ្រាបភាពធន់នឹងអាកាសធាតុទៅក្នុងផែនការអភិវឌ្ឍន៍ ក្នុងសមាសភាគយន្តការគាំទ្រសង្គមស៊ីវិល (MCRD-CSSM)។ គម្រោងបានផ្តល់មូលនិធិចំនួន៤២,៥៦៦.៨២ដុល្លារសហរដ្ឋអាមេរិកសម្រាប់អង្គការសហគមន៍ព្រៃឈើក្រាំងសេរី។ មូលនិធិខ្នាតតូចសម្រាប់គម្រោងរយៈពេល១៨ខែ គឺដើម្បីបង្កើនភាពធន់សហគមន៍ព្រៃឈើក្រាំងសេរីទៅនឹងឥទ្ធិពលនៃព្រឹត្តិការណ៍អាកាសធាតុ នៅក្នុងឃុំគិរីវន្ត ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ។ ជាមួយនឹងការគាំទ្រនេះសហគមន៍ព្រៃឈើក្រាំងសេរី នឹងធ្វើឱ្យប្រសើរដល់ការផ្គត់ផ្គង់ និងការគ្រប់គ្រងទឹក និងការលើកកម្ពស់ការងារកសិកម្មដែលបន្សាំនឹងអាកាសធាតុការអនុវត្តអនាម័យទឹកស្អាតនិងសុខភាពព្រមទាំងការពង្រឹងលើការគ្រប់គ្រងបរិស្ថានធម្មជាតិនៅក្នុងសហគមន៍ទាំងមូល។ គម្រោងនេះនឹងផ្តល់ផលប្រយោជន៍ដល់ប្រជាពលរដ្ឋចំនួន៤៣០គ្រួសារ នៅក្នុងភូមិចំនួន៣ ក្នុងចំណោមភូមិទាំង៩ ក្នុងឃុំគិរីវន្ត។

ដោយសារតែប្រភពទឹករីងស្ងួតដូចជា ស្រះ អាងស្តុកទឹក ឬប្រភពទឹកផ្សេងៗ សហគមន៍គីរីវន្ត ជួបប្រទះនូវកង្វះទឹកស្អាតប្រើប្រាស់តាមផ្ទះនីមួយៗ និងមិនអាចធ្វើការដាំដុះបាន ជាពិសេសនៅក្នុងរដូវប្រាំង។




ប្រជាពលរដ្ឋនៅទីនោះ ពឹងផ្អែកទាំងស្រុងលើការងារកសិកម្ម និងអនុផលព្រៃឈើសម្រាប់ផ្គត់ផ្គង់ជីវភាពរបស់ពួកគេ។ ការខ្វះខាតទឹក អាចមានផលប៉ះពាល់យ៉ាងខ្លាំងដល់ស្ត្រី និងកុមារដែលពួកគេត្រូវទៅដងទឹកពីទីកន្លែងឆ្ងាយ។ កុមារមួយចំនួនខកខានមិនបានទៅសាលារៀន ហើយស្ត្រីៗដែលមិនអាចរកចំណូលបាន ដើម្បីផ្គត់ផ្គង់គ្រួសាររបស់ខ្លួន ដោយសារត្រូវចំណាយពេលវេលាច្រើនម៉ោងទៅដងទឹក។

សុខភាព និងអនាម័យល្អមិនអាចធ្វើទៅបានទេ ដរាបណាមានការខ្វះខាតទឹកស្អាត។ ភូមិទាំង៣មានដូចជា ភូមិក្រាំងច្រេស ភូមិក្រាំងស្វា និងភូមិត្រពាំងក្រឡឹង ដែលជាទីតាំងគម្រោង មិនមានលទ្ធភាពក្នុងការរៀបចំស្រះបានឡើយ ហេតុដូច្នេះទើបសហគមន៍ព្រៃឈើក្រាំងសេរី បានលើកសំណើមកគម្រោងដើម្បីធ្វើការពង្រីកប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតដល់ភូមិរបស់ខ្លួន។

## សមិទ្ធផលថ្មីៗរបស់សហគមន៍ព្រៃឈើក្រាំងសេរី



ចាប់តាំងពីទទួលបានការចុះបញ្ជីរួចមកក្នុងឆ្នាំ២០១០ សហគមន៍ក្រាំងសេរី បានទទួលការគាំទ្រពីម្ចាស់ជំនួយផ្សេងៗ។ សហគមន៍មានភាពសកម្មលើការងារទឹកស្អាត សម្រាប់ប្រើប្រាស់ក្នុងផ្ទះ និងការងារកសិកម្ម។ វាជាសមិទ្ធផលមួយដ៏ធំដែលបានសាងសង់ និងពង្រីកអាងស្តុកទឹកមួយដែលមានទំហំ ៨០០,០០០ម៣ និងជាប្រព័ន្ធផ្គត់ផ្គង់ទឹកម៉ាស៊ីន ដែលអាចសម្រួលដល់ប្រជាពលរដ្ឋចំនួន១២៥គ្រួសារ ក្នុងភូមិចំនួន៣ខាងលើក្នុងឃុំគិរីវន្ត។ គ្រួសារនីមួយៗបង់សេវាតភ្ជាប់ក្នុងតម្លៃ ៥០ដុល្លារសហរដ្ឋអាមេរិក (ហើយក៏មានការបញ្ចុះតម្លៃពិសេសសម្រាប់គ្រួសារក្រីក្រ) និងការបង់ប្រាក់សម្រាប់ការប្រើប្រាស់ទឹកប្រចាំខែ។ អង្គការសហគមន៍មូលដ្ឋានមួយនេះ បានចំណាយថវិកាសម្រាប់ថែទាំប្រព័ន្ធទឹកស្អាត និងប្រមូលថ្លៃឈ្នួលទៅតាមគ្រួសារនីមួយៗប្រើប្រាស់ដែលគិតជាម៉ែត្រគូប។



ការមានប្រព័ន្ធទឹកម៉ាស៊ីនប្រើប្រាស់ បានធ្វើឱ្យ មានការប្រែប្រួលដល់ការរស់នៅរបស់ប្រជាពលរដ្ឋ ដែលញ៉ាំងឱ្យពួកគេរីករាយក្នុងការចូលរួម និងបង់ប្រាក់ក្នុងការអនុវត្តគម្រោងទឹកស្អាតមួយនេះ។ លើសពីនេះទៀត ពេលមានទឹកប្រើប្រាស់ប្រជាពលរដ្ឋអាចរៀបចំសួនបន្លែ និងចិញ្ចឹមសត្វបាន។ ដោយមានការគាំទ្រពីអង្គការទស្សនៈពិភពលោកកម្ពុជាអង្គការសហគមន៍មូលដ្ឋាននេះ បានរៀបចំផលិតកម្មទឹកស្អាតច្រកដប និងធ្វើការចែកចាយដល់សាលារៀន វត្ត ដែលក្រុមអតិថិជនប្រចាំ។

កាលពីឆ្នាំកន្លងមក អង្គការសហគមន៍មូលដ្ឋាននេះ បានបង្កើតនិងគាំទ្រដល់ក្រុមសន្សំប្រាក់ចំនួន៤ក្រុម ដែលបង្កើតឡើងក្នុងសហគមន៍ផ្ទាល់ ហើយមកដល់ពេលនេះ ក្រុមទាំងនោះមានថវិកាសមល្មមសម្រាប់ខ្លួនឯង(ទាំង៤ក្រុមមានថវិកាសរុបរហូតដល់ ១០,០០០ដុល្លារសហរដ្ឋអាមេរិក) ដែលពួកគេមិនចាំបាច់ខ្ចីពីអង្គការសហគមន៍មូលដ្ឋានទៀតឡើយ ទោះបីយ៉ាងណាពួកគេក៏នៅមានទំនាក់ទំនងជាមួយគ្នាដូចជាការផ្តល់ប្រាក់ឥណទានទៅឱ្យសហករណ៍កសិកម្ម។

## គម្រោងថ្មីៈ ធ្វើឱ្យប្រសើរឡើងថែមទៀតដល់សហគមន៍ឱ្យធន់នឹងអាកាសធាតុតាមរយៈការរៀបចំ និងការផ្គត់ផ្គង់ទឹក



បើទោះជាឆ្នាំចុងក្រោយនេះ សហគមន៍ជួបប្រទះគ្រោះរាំងស្ងួតដ៏ធ្ងន់ធ្ងរក៏ដោយ អាងស្តុកទឹកមេនៅតែអាចផ្គត់ផ្គង់ទឹកសម្រាប់ការប្រើប្រាស់ពេញមួយរដូវប្រាំង។ បរិមាណទឹកអាង នៅតែអាចផ្គត់ផ្គង់សម្រាប់ការប្រើប្រាស់ប្រចាំខែគ្រប់គ្រាន់ ទាំងតាមផ្ទះ និងសួនដំណាំ ប៉ុន្តែមិនអាចស្រោចស្រពដំណាំនៅរដូវប្រាំងបានទេ។ តែទោះជាយ៉ាងណា កាលពីប៉ុន្មានខែមុនអាងស្តុកទឹកបានរីងស្ងួត ហើយប្រជាពលរដ្ឋជួបការលំបាកខ្លាំងក្នុងការយកទឹកមកប្រើប្រាស់។ នៅខេត្តកំពង់ស្ពឺ ការធ្លាក់ភ្លៀងមានភាពយឺតយ៉ាវ ហើយប្រជាពលរដ្ឋក្នុងសហគមន៍ ត្រូវតែទៅយកទឹកពីអណ្តូងស្នប់ដើម្បីប្រើប្រាស់ ហើយអ្នកភូមិដទៃទៀតក៏មិនអាចប្រើប្រាស់ទឹកម៉ាស៊ីនបានដែរ។

ដើម្បីកសាងសហគមន៍ឱ្យមានភាពធន់នឹងការប្រែប្រួលអាកាសធាតុធ្ងន់ធ្ងរ កញ្ចប់មូលនិធិដែលគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី (កម្មវិធីយុទ្ធសាស្ត្រសម្រាប់ភាពធន់នឹងអាកាសធាតុ) តាមរយៈអង្គការផ្លែនអន្តរជាតិកម្ពុជា អាចនឹង៖

- ពង្រីកប្រព័ន្ធចែកចាយទឹកដល់ប្រជាពលរដ្ឋចំនួន ៤៧១គ្រួសារ
- ផ្តល់ម៉ាស៊ីនបូមទឹកធំមួយ និងពង្រីកទំហំអាងស្តុកទឹកពី១២,០០០ម$^{៣}$ ទៅ ២១,០០០ម$^{៣}$ ដែលអាងស្តុកទឹកទី២នៅផ្នែកខាងក្រោម។ អាងស្តុកទឹកតូចនេះ អាចឆាប់ទទួលបានទឹកលឿនជាងអាងធំនៅផ្នែកខាងលើ ព្រោះចំផ្ទៃមុខទឹកល្អជាង។ នៅពេលចាំបាច់ គេនឹងបូមទឹកពីអាងតូចខាងក្រោមនេះ ទៅបំពេញអាងធំខាងលើ ដែលអាចសម្រួលដល់ការប្រើប្រាស់បានទូលំទូលាយជាងមុន។



- គម្រោងនឹងគាំទ្រការពង្រឹងឱ្យមានភាពធន់ និងសមត្ថភាពរបស់អង្គការសហគមន៍មូលដ្ឋាន ដល់អាជ្ញាធរមូលដ្ឋាន និងក្រុមអ្នកប្រើប្រាស់ទឹក ដើម្បីឱ្យគេអាចធ្វើការជាមួយគ្នាយ៉ាងមានប្រសិទ្ធិភាព និងមានតម្លាភាពក្នុងការគ្រប់គ្រងប្រព័ន្ធទឹកប្រកបដោយនិរន្តរភាព ក្នុងការប្រើប្រាស់បរិមាណទឹក ពិសេសក្នុងរដូវកាលដែលខ្វះខាតទឹកខ្លាំង។

## ព្រៃឈើ

បេសសកម្មរបស់សហគមន៍ព្រៃឈើក្រាំងសេរី គឺការការពារព្រៃសហគមន៍ ដោយគាំទ្រឱ្យមានការទទួលបានប្រយោជន៍ពីអនុផលព្រៃឈើ សម្រាប់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។ ប៉ុន្មានឆ្នាំនេះ អង្គការសហគមន៍មូលដ្ឋាន (សហគមន៍ព្រៃឈើក្រាំងសេរី) បានចំណាយថវិកាក្នុងការឃ្លាំមើលឬល្បាត និងធ្វើយុទ្ធនាការថែរក្សាព្រៃសហគមន៍ និងធនធានទឹក។

លោក ឡុង ធីម ដែលជាប្រធានសហគមន៍ព្រៃឈើក្រាំងសេរី បានពន្យល់ថា “បួនឬប្រាំគ្រួសារដែលឧស្សាហ៍ចូលព្រៃ ដើម្បីប្រមូលអនុផលព្រៃឈើ មានដូចជាទឹកឃ្មុំ បន្លែព្រៃ អាចបញ្ឈប់ពួកគេពីការប្រមាញ់ និងកាប់ឈើខុសច្បាប់បាន”។ មូលនិធិ ដែលជាជំនួយពីធនាគារអភិវឌ្ឍន៍អាស៊ី នឹងផ្តល់ជាគ្រាប់ពូជ ការដាំដើមឈើដល់ភូមិទាំង៤ ជាពិសេសជុំវិញបរិវេណសាលា ព្រៃសហគមន៍ និងអាងស្តុកទឹក។ អង្គការសហគមន៍មូលដ្ឋាននេះក៏គាំទ្រផ្នែកស្មារតីលើការការពារព្រៃឈើ ពីរដងជារៀងរាល់ឆ្នាំ ដោយប្រើប្រាស់ប្រាក់ចំណេញពីសកម្មភាពចែកចាយទឹក។

### សកម្មភាពដទៃទៀត

ដើម្បីទទួលបាននូវអត្ថប្រយោជន៍ជាអតិបរមាពីសេដ្ឋកិច្ចសង្គម គម្រោងនឹងរៀបចំការលើកកម្ពស់ការយល់ដឹងដល់សហគមន៍ពីការបន្សាំនឹងការប្រែប្រួលអាកាសធាតុ អាហារូបត្ថម្ភ គម្រោងទឹកស្អាត និងអនាម័យ និងការផ្តល់វគ្គបណ្តុះបណ្តាលផ្សេងៗជាប្រយោជន៍ក្នុងការគាំទ្រលើសួនបន្លែរៃយឆ្លាតធន់នឹងអាកាសធាតុ។






## ការផ្តួចផ្តើមរៀបចំផែនការភាពធន់នឹងអាកាសធាតុនៅថ្នាក់ក្រោមជាតិសមធម៌មយេនឌ័រ និងការតាមដានត្រួតពិនិត្យគម្រោងវិនិយោគការបន្សាំត្រូវបានចាប់ផ្តើមអនុវត្ត

កាលពីថ្ងៃទី១ខែកក្កដា កន្លងមកនេះ ការបញ្ជ្រាបភាពធន់នឹងអាកាសធាតុទៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍៖ យេនឌ័រ ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ និងការបញ្ជ្រាបនៅថ្នាក់ក្រោមជាតិត្រូវបានចាប់ផ្តើមអនុវត្ត។ ការផ្តួចផ្តើមនេះត្រូវបានអនុវត្តដោយនាយកដ្ឋានប្រែប្រួលអាកាសធាតុ ជាមួយគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ក្រសួងកិច្ចការនារី និងក្រសួងផែនការ ដែលមានអង្គការ UN-Habitat អង្គការ Forum Syd និងអង្គការ Save the Earth Cambodia ជាអ្នកគាំទ្របច្ចេកទេសដល់ការអនុវត្ត។ គម្រោងដែលមានរយៈពេលបីឆ្នាំ (ខែសីហា ឆ្នាំ២០១៦-២០១៩) នឹងផ្តល់លទ្ធផលសំខាន់ចំនួន៣ពាក់ព័ន្ធនឹងការបញ្ជ្រាបភាពធន់នឹងអាកាសធាតុនៅថ្នាក់ក្រោមជាតិ ការដាក់បញ្ចូលយេនឌ័រទៅក្នុងការរៀបចំផែនការបន្សាំ និងការតាមដានត្រួតពិនិត្យនិងវាយតម្លៃគម្រោងវិនិយោគការបន្សាំ។

១. **ការបញ្ជ្រាបភាពធន់នឹងអាកាសធាតុនៅថ្នាក់ក្រោមជាតិ ក្នុងកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយអគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ** នឹងកាត់បន្ថយភាពងាយរងគ្រោះនៅកម្រិតស្រុក និងឃុំក្នុងខេត្តដែលបានជ្រើសរើសដោយបង្កើនសមត្ថភាពដល់អាជ្ញាធរមូលដ្ឋានដើម្បីបញ្ជ្រាបភាពធន់នឹងអាកាសធាតុទៅក្នុងការរៀបចំផែនការនៅថ្នាក់ក្រោមជាតិ។ សកម្មភាពរួមមាន៖
   - ការដាក់បញ្ចូលការគ្រប់គ្រងហានិភ័យអាកាសធាតុទៅក្នុងផែនការ កម្មវិធី និងគម្រោងអភិវឌ្ឍន៍ស្រុក និងឃុំ
   - ការរៀបចំវគ្គបណ្តុះបណ្តាល និងឯកសារណែនាំ
   - ការប្រើប្រាស់ឧបករណ៍ជ្រើសរើសហានិភ័យអាកាសធាតុសម្រាប់វាយតម្លៃការបន្សាំនៅថ្នាក់ក្រោមជាតិ និង
   - ការសាកល្បងសកម្មភាពការបន្សាំនៅកម្រិតឃុំ និងស្រុក

២. **ដាក់បញ្ចូលការគិតគូរពីយេនឌ័រទៅក្នុងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ ក្នុងកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយក្រសួងកិច្ចការនារី** នឹងបង្កើនសមត្ថភាពបន្សាំរបស់ស្ត្រី ដើម្បីដោះស្រាយផលប៉ះពាល់ការប្រែប្រួលអាកាសធាតុដោយធ្វើឱ្យប្រសើរឡើងសមត្ថភាពស្ថាប័ន និងបច្ចេកទេសនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិក្នុងការបញ្ជ្រាបបញ្ហាយេនឌ័រសម្រាប់ការបន្សាំ។ សកម្មភាពសំខាន់រួមមាន៖
   - ការគាំទ្របច្ចេកទេសដើម្បីកែសម្រួល និងអនុវត្តផែនការមេយេនឌ័រ និងការប្រែប្រួលអាកាសធាតុ
   - ការដាក់បញ្ចូលបញ្ហាយេនឌ័រទៅក្នុងផែនការសកម្មភាពការប្រែប្រួលអាកាសធាតុយ៉ាងហោចណាស់នៅក្នុងវិស័យបី រួមមានកសិកម្ម ធនធានទឹក និងសុខភាព
   - ការបង្កើតឯកសារណែនាំ និងកម្មវិធីផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹងស្តីពីការបញ្ជ្រាបយេនឌ័រទៅក្នុងការបន្សាំសម្រាប់ក្រសួងកិច្ចការនារី និងក្រសួងវិស័យសំខាន់ៗ
   - ការអនុវត្តការសាកល្បងការបន្សាំប្រកបដោយសមធម៌យេនឌ័រ និងការរៀបចំករណីសិក្សាការវិភាគសេដ្ឋកិច្ចសម្រាប់ការបញ្ជ្រាបយេនឌ័រក្នុងគម្រោងបន្សាំ

**៣. ការធ្វើរបាយការណ៍តាមដានត្រួតពិនិត្យ និងវាយតម្លៃប្រសិទ្ធភាពគម្រោងវិនិយោគការបន្សុំាក្នុងកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយក្រសួងផែនការ** និងវាយតម្លៃប្រសិទ្ធផលថវិកាបន្សុំា និងប្រសិទ្ធភាពនៃការអន្តរាគមន៍ដើម្បីឈានទៅសម្រេចគោលបំណងរបស់គម្រោង ការតាមដានត្រួតពិនិត្យ ការធ្វើរបាយការណ៍ និងការវាយតម្លៃគឺមានសារៈសំខាន់ណាស់ និងគួរត្រូវបានដាក់បញ្ចូលទៅក្នុងការរៀបចំយុទ្ធសាស្ត្រ ផែនការ កម្មវិធី និងគម្រោងការប្រែប្រួលអាកាសធាតុ។ ផ្នែកនេះនឹងមានសកម្មភាពដូចជាការកសាងសមត្ថភាពនៅតាមក្រសួងក្នុងការគ្រប់គ្រងទិន្នន័យការប្រែប្រួលអាកាសធាតុ និងដាក់បញ្ចូលការបន្សុំាពាក់ព័ន្ធនឹងសូចនាករទៅក្នុងការរៀបចំផែនការនៅថ្នាក់ក្រោមជាតិ និងគម្រោងវិនិយោគ។

## សកម្មភាពថ្មីៗក្នុងក្រសួងផែនការ ក្រសួងកិច្ចការនារី និង គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ



សកម្មភាពបន្ថែមក្រោមការបញ្ជ្រាបភាពធន់នឹងអាកាសធាតុទៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍ បានចាប់ផ្តើមដំណើរការក្នុងខែសីហាឆ្នាំ២០១៦ បន្ទាប់ពីចុះកិច្ចព្រមព្រៀងជំនួយសហប្រតិបត្តិការបច្ចេកទេសរវាងធនាគារអភិវឌ្ឍន៍អាស៊ី និងក្រុមការងារដែលដឹកនាំដោយអង្គការ UN-Habitat អង្គការ Forum Syd និង អង្គការ Save the Earth Cambodia ។

ក្រុមអ្នកជំនាញបានចាប់ផ្តើមធ្វើការក្នុងខែសីហា។ កិច្ចប្រជុំណែនាំក្រុមការងារ បានដឹកនាំដោយឯកឧត្តម សាយ សំអាល់ រដ្ឋមន្ត្រីក្រសួងបរិស្ថានកាលពីថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៦។ ឯកឧត្តមបានស្វាគមន៍ដល់ការចាប់ផ្តើមអនុវត្តសកម្មភាពបន្ថែមនេះ និងបានផ្តល់អនុសាសន៍ណែនាំមួយចំនួនដល់ក្រុមការងារ ដោយសង្កត់ធ្ងន់លើតម្រូវការសកម្មភាពបន្សុំាអាទិភាពដែលជួយកាត់បន្ថយភាពងាយរងគ្រោះផ្ទាល់ក្នុងសហគមន៍ ជាឧទាហរណ៍ ការធ្វើឱ្យប្រសើរឡើងភាពមានទឹកគ្រប់គ្រាន់សម្រាប់ការប្រើប្រាស់។

ក្រុមការងារកំពុងធ្វើការសិក្សាវាយតម្លៃតម្រូវការសមត្ថភាពរបស់ក្រសួងវិស័យ អង្គការសង្គមស៊ីវិល និងអាជ្ញាធរនៅថ្នាក់ក្រោមជាតិ។ របាយការណ៍ចាប់ផ្តើមអនុវត្តគម្រោងនឹងត្រូវបានបញ្ចប់នៅពាក់កណ្តាលខែតុលា ហើយសិក្ខាសាលាក៏ត្រូវបានគ្រោងរៀបចំនៅចុងខែតុលាផងដែរ។

ADB

CLIMATE INVESTMENT FUNDS

**ព័ត៌មានបន្ថែម៖**
ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត សាបូ អូហ្សាណូ រដ្ឋលេខាធិការក្រសួងបរិស្ថាន និងជាប្រធានសម្របសម្រួលកម្មវិធី
លោក មាស សុផល នាយកដឹកនាំកម្មវិធី
លោក អ៊ូ ច័ន្ទដារិទ្ធ ប្រធានគ្រប់គ្រងកម្មវិធី
អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព
នាយកដ្ឋានប្រែប្រួលអាកាសធាតុ
អគារមរតកតេជោ ឡូតិ៍លេខ៥០៣ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ប្រទេសកម្ពុជា
ទូរស័ព្ទ៖ ៨៥៥ ២៣ ៥៣១៤ ៧៧៧
អ៊ីម៉ែល៖ adbspcrta8179@gmail.com
គេហទំព័រ៖ http://www.spcrcambodia.org/kh/